# សេចក្តីថ្លែងការណ៍រួម

នេះគឺជាសេចក្តីថ្លែងការណ៍រួម រវាងធនាគារហត្ថា (HTB) និង ដើមបណ្តឹង ពាក់ព័ន្ធនឹងការវិនិយោគរបស់ IFC ជាមួយធនាគារហត្ថា ក្នុងប្រទេសកម្ពុជា (លេខគម្រោង IFC 44742)។ ពាក្យបណ្តឹងនេះ ត្រូវបានដាក់ឈ្មោះសម្គាល់ថា "Cambodia: HTB Sub Debt-15"។

ក្នុងអំឡុងពេលនៃដំណើរការវាយតម្លៃរបស់ CAO ដើមបណ្តឹង និងអតិថិជនរបស់ IFC គឺ ធនាគារហត្ថា (HTB) បានសម្តែងការចាប់អារម្មណ៍ ចូលរួមក្នុងដំណើរការដោះស្រាយវិវាទដែលសម្របសម្រួលដោយ CAO ដើម្បីដោះស្រាយបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹងពាក់ព័ន្ធនឹងធនាគារហត្ថា ដោយប្រើប្រាស់វិធីសាស្ត្រដែលមានការចូលរួមសហការ។ ភាគីទាំងពីរបានឯកភាពលើវិធានជាមូលដ្ឋានសម្រាប់ការសម្រុះសម្រួល នៅក្នុងខែមករា ឆ្នាំ២០២៦។

ជាលទ្ធផលនៃការចូលរួមដោះស្រាយវិវាទដោយស្ម័គ្រចិត្តនេះ ភាគីទាំងពីរបានឈានដល់ និងបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយ នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៦ និងបានឯកភាពថារយៈពេលតាមដានការអនុវត្តកិច្ចព្រមព្រៀងដោះស្រាយវិវាទនេះ គឺសម្រាប់រយៈពេល ១៨ ខែ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៧ ជាមួយនឹងលទ្ធភាពអាចបន្តរយៈពេលតាមដាននេះបាន។

បន្ថែមពីនេះ ភាគីទាំងពីរ និងតំណាងរៀងៗខ្លួន បានឯកភាពរក្សាការសម្ងាត់នៃខ្លឹមសាររបស់កិច្ចព្រមព្រៀង ដើម្បីគោរពដល់ឯកជនភាពនៃដំណើរការនេះ ការពារព័ត៌មានរសើបផ្នែកពាណិជ្ជកម្ម និងគោរពដល់ការយោគយល់គ្នាទៅវិញទៅមករវាងភាគីទាំងពីរ។

Pay ហ៊ុំ ពៅ

ប្រាក់.សុវណ្ណណារិ
ធនាគារហត្ថា ម.ក

Official Use Onl